វិធានការបីយ៉ាង ?

វិធានការបីយ៉ាង ?

លោក សម រង្សី ដែល ទុកខ្លួនលោកជា អ្នកអាណិតអាសូរ គណបក្សសង្គ្រោះជាតិ សុខចិត្តលាងារពី ប្រធាន និងសមាជិកបក្ស ដើម្បី សង្គ្រោះគណបក្ស កុំ១ លោក ហ៊ុន សែន រំលាយ។ ទង្វើនោះ វាជាវីរកម្ម ផ្ទៃផ្ទរ បើជាមូលហេតុពិត តែតាមការពិត គាត់ត្រូវតែលាលែង ពុំនោះសោត ក៏ពួកអ្នកដឹកនាំបក្ស នៅពេលនោះ គេទំលាក់គាត់ដែរ ដើម្បី តម្រូវនឹង សេចក្ដីចង់បាន របស់លោក ហ៊ុន សែន។ ការលាលែង ដោយអាស្រ័យហេតុផ្ទាល់ខ្លួន របស់លោក សម រង្សី ដែលគាត់យកវាមកបកស្រាយថា ជាវីរកម្ម ដូចខាងលើនេះ បញ្ជាក់១ឃើញថា គាត់ជា មនុស្សរេតាមខ្យល់ ឆ្លៀតឱកាស ក្នុង បរិបទនយោបាយសព្វថ្ងៃ តែ ទ្ទូរ បរាជ័យផ្ទាល់ខ្លួន របស់គាត់ អោយទៅជា ពលិកម្ម ចំពោះ គណបក្ស ទៅវិញ។ តែ ទង្វើ បន្ទាប់ៗមក របស់គាត់ វាបរិហារ ទ្ទូរ គំនិតខ្ចៅរបស់គាត់ ដូចយ៉ាង នៅពេលចុងក្រោយ ប្រកាសថា ខ្លួនវិលត្រឡប់មកចូលជា សមាជិកបក្សវិញ ហាក់ បីដូចជា ការចេញចូល ក្នុង គណបក្ស វាដូចគេ ចេញចូលក្នុង បនស្រីពេស្យា។ សួរថា តើការវិលត្រឡប់វិញនៅពេលនោះ វាជា ការសង្គ្រោះ ជាថ្មី ដល់ គណបក្ស មុនមួយថ្ងៃ ដែល តុលាការ ហ៊ុនសែន រំលាយបក្ស ? ចេញក៏ថាជាការសង្គ្រោះ ចូលក៏ថាជា

វិធានការបីយ៉ាង ?

ការសង្គ្រោះ តើអ្វីមួយជាការពិត ? នេះហើយ ជាបញ្ហាចិត្ត និយម របស់លោក សម រង្សី គឺ ភាពប្រែប្រួល ឬ ភាពទេទើរ របស់គាត់។

ឥឡូវនេះ លោក សម រង្សី ដដែលនេះ ចេញដើរតួជាថ្មី ជា អ្នកសង្គ្រោះជាតិ, សង្គ្រោះលទ្ធិប្រជាធិបតេយ្យ ប្រកាស ជាសាធារណៈ នូវ វិធានការសើន[1] បីយ៉ាង : បដិសេធ នូវ ការវិនិច្ឆ័យ

របស់តុលាការ, រក្សា នូវ រចនាសម្ព័ន្ធគណបក្ស និង បំរុងនឹងចរចា ជាមួយ លោក ហ៊ុន សែន ក្នុងថ្នាក់អន្តរជាតិ។ យើងឃើញថា ប្រធានបទ នៃ ការចរចា ដែល លោក សម រង្សី លើកមកនិយាយដដែល ហាក់បីដូចជាគាត់ មាន កម្លាំងពិសេសអ្វីមួយ អាចបញ្ឈប់ នូវ ចរន្ត នៃ អំណាចផ្តាច់ការ ឲឈប់ហូរ ហើយវិលត្រឡប់មកចរចា ជាមួយគាត់ ដែលជា បុគ្គលម្នាក់ គ្មាន គម្នាស់អ្វីមួយពិតប្រាកដ សំរាប់ គំរាមដល់អំណាចផ្តាច់ការ។ ការចរចា អាចមានបាន លុះត្រាតែ ភាគីនិមួយៗ មានកម្លាំង ស្មើគ្នា។ ជាឧទាហរណ៍ បើ ហ៊ុន សែន មានទ័ព, សម រង្សី ត្រូវមាន ប្រជាការសកម្ម ដើបប្រឆាំងនឹងអំណាចព្រៃ។ ការលើកថា គណបក្សសង្គ្រោះជាតិ មាន ខ្ទេរ បីលាននាក់ ចោះ ឆ្នោតអោយ ជាការរក សេចក្ដីសំអាង តាមផ្លូវច្បាប់ នៅក្នុងក្របខណ្ឌច្បាប់។ តែត្រូវដឹងថា នៅក្នុងរបបផ្តាច់ការ ច្បាប់រាជាអារុជ សំរាប់បំរើអំណាច ហើយច្បាប់ជាច្រើន ដែលបង្កើត

[1] វិធានការសើន; mesure phare។

វិធានការបីយ៉ាង ?

ឡើង ដោយគណបក្សកាន់អំណាចផ្តាច់ការ គឺមាន ពួកអ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ ជាអ្នកចូលរួមចំណែកទាំងស្រុង ព្រោះខ្លួនបាននាំគ្នាធ្វើឲរដ្ឋសភាចោរ ឲក្លាយជារដ្ឋសភាជាតិ។ ពិតមែនតែមានពហិការ មិនចូលបោះឆ្នោត តែពួកខ្លួនបាន ឲ សុពលភាព ដល់តម្លៃ នៃ ការបោះឆ្នោតសភា រួចទៅហើយ។ ដូចមានគំនិតមួយ គេនិយាយថា នៅពេលដែលអវិជ្ជា វាមាននៅក្នុងសង្គម ហើយ គំនិតរាត់រាយ វាមាននៅក្នុងស្មារតីពួកនយជន គឺវាមានកើតច្បាប់ជាច្រើន ជាពុំខាន គឺមានន័យថា ច្បាប់ទាំងនោះ មិនមែនជាច្បាប់ សំរាប់ ការពារសង្គម និង ការពារ ស្មារតី នៃ សិទ្ធិ នៃ ពលរដ្ឋនោះឡើយ ព្រោះច្បាប់ទាំងនោះ វាមានធាតុ ជា ភាពខ្លៅ និង ការច្រឡំបល់។ ត្រូវដឹកថា បើមានពលរដ្ឋបីលានបោះឆ្នោតអោយ តែអកម្ម នៅចំពោះមុខ ការបំពានជាក់ស្តែង ដល់ អំណាចឆ្នោតរបស់ខ្លួន ពីសំណាក់ពួកជនផ្តាច់ការ គឺថា ការចូលរួម បោះឆ្នោត របស់ខ្លួន វាអាចចាត់ទុកជាអវិជ្ជាបាន។

ដូច្នេះ ការលើក ចំណុច នៃ ការចរចា មកធ្វើជា វិធានការ ដោយគ្មានកម្លាំងនយោបាយអ្វីសោះ គឺ វានាំបង្កើត នូវ ការ ច្របូកច្របល់ នៅក្នុងស្មារតី ពួកអ្នកគាំទ្រខ្លួន និង ប្រជាជនរងគ្រោះ ពីសំណាក់អំណាចផ្តាច់ការទៅវិញទេ គឺពោលថា កុំនាំគ្នាធ្វើអ្វីឲសោះ ព្រោះវានឹងមាន ការចរចា រវាង គណបក្ស នឹង គណបក្ស។ ការណ៍នេះ វានាំឲនឹកឃើញដល់ រឿងធម៌សន្ទនា

វិធានការបីយ៉ាង ?

ដែលនាំគ្នាចរចា បំពានលើ ម្ចាស់ឆ្នោត ដោយតតមានការ អៀនខ្មាស់សោះឡើយ។ លោក សម រង្សី គួរដឹងថា អ្វីដែលលោក បានធ្វើខុស វាមិនអាចលុបបាត់នោះឡើយ ហើយ លោក មិន អាចយកវាមកលក់ ឬ ជោកប្រាស់ជាថ្មីបានម្តងទៀតនោះទេ។ ការចរចា ជាមួយ អំណាចផ្តាច់ការ គឺវាគ្រាន់តែជា វិធានការ សំរាប់ដោះស្រាយបញ្ហានយោបាយ មួយរយៈពេលតែប៉ុណ្ណោះ តែ វាមិនអាច រំលាយ របបផ្តាច់ការបានជាដាច់ខាត។ មេក្រមី បើ វាមិនស្លាប់ គឺ វានឹងកើតរាលដាលពេញខ្លួន ហើយ អាចក្លាយ ជា ជំងឿមហារីកតែម្តង។

ដំណោះស្រាយពិត គឺស្ថិតនៅលើ កម្លាំងប្រជាពលរដ្ឋខ្មែរ ដើប តស៊ូ ជាប្រជាយាត្រា របស់ មហាបដិវត្តន៍ ដែលធ្លាប់កើតមាន នៅក្នុង ប្រវត្តិសាស្ត្រ នៃ មនុស្សជាតិ ដើម្បី រំលំ របបផ្តាច់ការ។ បើគាត់មិនកំរើក គឺច្បាស់ ជា លោក ហ៊ុន សែន គាត់សំរាន លក់ស្រួល នៅពេលដែល ជនជាតិយួន រាប់លាននាក់ បន្តដើរ ចូលមករស់នៅក្នុងស្រុកខ្មែរ បានតាមសេរី។ លោក ហ៊ុន សែន គាត់អត់ឈឺក្បាល អំពីរឿងទាំងឡាយនោះទេ ក៏ដូចគ្នានឹង លោក សម រង្សី នោះដែរ ព្រោះ វាមាន ការចរចា ជាការ សូមចុះ ចាញ់ ជាថ្មីទៀតតែប៉ុណ្ណោះ សំរាប់ដោះស្រាយ ព្រោះ ក្ងានសោ នៃ បញ្ហា វានៅក្នុងដៃលោក ហ៊ុន សែន។ រីឯ លោក សម រង្សី វិញ គាត់ក្ខានផ្សៀ សំរាប់ធ្វើនំ ក្រៅតែបន្តដេកចាំ ការផ្ទួតផ្ដើម នៃ ដំណោះស្រាយ ពីសំណាក់លោក ហ៊ុន សែន ដូចសព្វដងតែ

វិធានការបីយ៉ាង ?

ប៉ុណ្ណោះ។ ការណ៍នេះ ត្រូវប្រជាពលរដ្ឋខ្មែរ ដឹងខ្លួន បើនៅតែនាំគ្នា ដេកចាំតែបោះឆ្នោត ឬ សង្ឃឹម លើ ពួកអ្នកដឹកនាំ បក្សសង្គ្រោះជាតិ គឺពិតជាឆោត នៅចំពោះមុខជនជាតិយួន មានសញ្ញាតិកម្ពុជា ជាពុំខាន។ ខ្មែរម្នាក់ៗ មិនមែនមើលមិនឃើញទេ មុខ ពួកអ្នកដឹកនាំនៅស្រុកខ្មែរ គឺ សុទ្ធតែយួនស្ទើតែទាំងអស់ទៅហើយ សូម្បី មេឃុំ ក៏ជាជនជាតិយួនដែរ ទាំងនៅក្នុងជួរ គណបក្សកាន់អំណាច និង សង្គ្រោះជាតិ។ ការកត់សំគាល់នេះ មិនមានកំនិតប្រកាន់ពូជសាសន៍នោះឡើយ តែជា ការឈឺចាប់ ថា តើជាតិសាសន៍ខ្មែរយើង អីក៏អន់ម្លេះ ទុកឲ្យប្រជាជាតិខ្លួនធ្លាក់ដល់កំរិត ជា ប្រជាជាតិខ្ទុំបរទេស ស្ទើតែគ្មានកម្លាំងខ្លួនឯងជាទីរំពឹង ហើយនាំគ្នាបន្ត រស់នៅក្រោមរបបអំណាចផ្តាច់ការ រួចនាំគ្នា សង្ឃឹមទៅលើ ពួកនយជន (hommes politiques) ប្រណ្ហោះគ្នា រករស់ ស្តាប់ សំដី សហគមអន្តរជាតិ ហើយយកមក កុហក ខ្មែរគ្នាឯង ថាជា ការសង្គ្រោះជាតិ។ ខ្មែរយើងម្នាក់ៗ ត្រូវសួរខ្លួនឯង ថា សព្វថ្ងៃ ខ្លួនមានប្រជាជាតិដែរឬទេ ឬគ្រាន់តែ រស់ តែមួយតែប៉ុណ្ណោះ ? បើរស់បានដូច្នោះ នាំគ្នាយល់ឃើញថា រាគ្រប់គ្រាន់សំរាប់ជីវិតដូច្នេះ ការដឹកនាំ របស់លោក ហ៊ុន សែន ក៏រាល្មមនឹងរស់បាននោះដែរ។ គំនិតនេះឯង ដែលគេហៅថា អត្តង្គតជាតិ គឺថា ទុក លោក ហ៊ុន សែន ជាអនាគត របស់ខ្លួន នឹង ប្រជាជាតិ តែម្តង។